

មូលដ្ឋានគ្រឹះនៃពិធីលៀងព្រះអម្ចាស់



ការបង្រៀនតាមរយៈសំបុត្រ ដោយ ដេរេក ព្រីនស៍

នៅក្នុងសៀវភៅ “អំណាចនៃពិធីលៀងព្រះអម្ចាស់” លោកដេរេក ព្រីនស៍ បានបង្រៀនអំពីចំណុចសំខាន់នៃទិដ្ឋភាពទាំងប្រាំពីរ អំពីពិធីបរិសុទ្ធដ៏សំខាន់នេះ ក្នុងសេចក្តីជំនឿគ្រីស្ទបរិស័ទ។ ខ្លឹមសារនៃសេចក្តីបង្រៀនប្រចាំខែ ដែលមានចំណងជើងថា “មូលដ្ឋានគ្រឹះនៃពិធីលៀងព្រះអម្ចាស់” បានផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ទិដ្ឋភាពទាំងប្រាំពីរ ដែលគាត់បានបំផុសបន្ថែមក្រោយមកទៀត។

ពិធីបរិសុទ្ធដ៏អស្ចារ្យ

ពាក្យមួយចំនួនដែលព្រះយេស៊ូវមានបន្ទូល ហើយពោរពេញដោយសេចក្តីស្រឡាញ់ និងប៉ះពាល់ដល់ចិត្តមនុស្សបំផុត គឺ៖

> “ចូរធ្វើពិធីនេះ ដើម្បីរំឭកពីខ្ញុំចុះ”។

ព្រះអង្គមានបន្ទូលពាក្យទាំងនេះនៅយប់មុនពេលទ្រង់ត្រូវគេឆ្កាង ខណៈដែលទ្រង់កំពុងកាច់នំបុ័ងជាមួយពួកសិស្ស នៅក្នុងបន្ទប់ខាងលើ។

ក្នុងប៉ុន្មានថ្ងៃចុងក្រោយនៃព្រះជន្មរបស់ទ្រង់នៅលើផែនដី ព្រះយេស៊ូវបានធ្វើគ្រប់ការទាំងអស់ដោយមានគោលបំណងយ៉ាងច្បាស់លាស់។ នៅពេលនោះ ទ្រង់បានតាំងពិធីដ៏បរិសុទ្ធមួយ ដែលជាពិធីដ៏មានតម្លៃនិងវិសេសបំផុតសម្រាប់សេចក្តីជំនឿគ្រីស្ទបរិស័ទរបស់យើង គឺ ពិធីលៀងព្រះអម្ចាស់។

ការជួបដ៏គួរឲ្យចាប់អារម្មណ៍

មនុស្សជាច្រើនប្រហែលជាគិតថា ការសិក្សាអំពីពិធីលៀងព្រះអម្ចាស់គួរតែចាប់ផ្តើមពីព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់នៅអាហារពេលល្ងាចចុងក្រោយ ដែលព្រះអង្គបានតាំងសញ្ញាថ្មីដោយការកាច់នំបុ័ង និងស្រាទំពាំងបាយជូរ។ ប៉ុន្តែ ខ្ញុំចង់ចាប់ផ្តើម ដោយពិនិត្យមើលអត្ថបទមួយពីសៀវភៅលោកុប្បត្តិ ជំពូក 14:17-24។ ខគម្ពីរទាំងនេះរៀបរាប់អំពីការជួបដ៏គួរឲ្យចាប់អារម្មណ៍មួយរវាងលោកអាប់រ៉ាម (មុនពេលព្រះទ្រង់ប្តូរឈ្មោះរបស់គាត់ទៅជា អ័ប្រាហាំ) និងបុគ្គលដ៏អស្ចារ្យ និងអាថ៌កំបាំងបំផុតម្នាក់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺ មិលគីស្សាដែក។

ទោះបីជាសំបុត្រទៅកាន់ជនជាតិហេព្រើរបាននិយាយអំពីមិលគីស្សាដែកយ៉ាងច្រើនក៏ដោយ ក៏គាត់នៅតែជាបុគ្គលដ៏អាថ៌កំបាំងម្នាក់។ មនុស្សជាច្រើនជឿថា ការលេចមករបស់មិលគីស្សាដែកនៅក្នុងលោកុប្បត្តិ ជំពូក ១៤ គឺជាការបង្ហាញអង្គទ្រង់ជាមុន (Christophany) ពោលគឺជាការលេចមករបស់ព្រះយេស៊ូវ មុនពេលទ្រង់យាងមកប្រសូតជាមនុស្ស។

អ្នកប្រហែលជាសួរថា៖ “ហេតុអ្វីបានជាអ្នកចាប់ផ្តើមប្រធានបទអំពីពិធីលៀងព្រះអម្ចាស់ ដោយប្រើបទគម្ពីរនេះ?” ខ្ញុំចង់ឲ្យអ្នកកត់សម្គាល់នូវចំណុចដ៏សំខាន់មួយ (ប្រសិនបើអ្នកមិនទាន់បានឃើញវា) គឺថា នៅក្នុងការជួបគ្នារវាងមិលគីស្សាដែក និងអាប់រ៉ាមនេះ មិលគីស្សាដែកបានយកនំបុ័ង និងស្រាទំពាំងបាយជូរមកជូនអាប់រ៉ាម។ និមិត្តសញ្ញាទាំងពីរនេះ គឺជានិមិត្តសញ្ញាដដែល ដែលស្ថិតនៅជាចំណុចកណ្តាលនៃពិធីលៀងព្រះអម្ចាស់ ដែលក្រុមជំនុំគ្រីស្ទបរិស័ទធ្វើរហូតមកដល់សព្វថ្ងៃ។

ភាពជាសង្ឃរបស់លោក មិលគីស្សាដែក

ជាមួយសេចក្តីផ្តើមដ៏ខ្លីនេះហើយ ឥឡូវនេះ សូមយើងបង្វែរការយកចិត្តទុកដាក់ទៅកាន់បទគម្ពីរនៅក្នុងលោកុប្បត្តិ ជំពូក ១៤។ នៅពេលនោះ លោកអាប់រ៉ាមទើបតែបានសង្គ្រោះក្មួយរបស់គាត់ គឺលោកឡុត ព្រមទាំងក្រុមគ្រួសាររបស់ឡុត ដោយបានយកមនុស្សទាំងអស់ និងទ្រព្យសម្បត្តិទាំងអស់ ដែលត្រូវបានចាប់យកទៅក្នុងសង្គ្រាមនោះមកវិញ។ យើងនឹងបន្តសាច់រឿងនេះ ដោយចាប់ផ្តើមពីខទី១៨៖

> ហើយមិលគីស្សាដែកជាស្តេចក្រុងសាឡិម ក៏នាំយកនំបុ័ង និងស្រាទំពាំងបាយជូរមក ពីព្រោះទ្រង់ជាសង្ឃរបស់ព្រះដ៏ខ្ពស់បំផុត ទ្រង់ [មិលគីស្សាដែក] ប្រទានពរដល់គាត់ [អាប់រ៉ាម] ថា សូមឲ្យអាប់រ៉ាមបានពរពីព្រះដ៏ខ្ពស់បំផុត ជាម្ចាស់នៃស្ថានសួគ៌នឹងផែនដី ហើយសូមព្រះដ៏ខ្ពស់បំផុតបានប្រកបដោយព្រះពរ ជាព្រះដែលបានប្រគល់ខ្មាំងសត្រូវមកក្នុងកណ្តាប់ដៃឯងរួច គាត់ [អាប់រ៉ាម] ក៏ថ្វាយ១ភាគក្នុង១០ ពីគ្រប់របស់ទាំងអស់ដល់ទ្រង់ [មិលគីស្សាដែក]។ (ខ 18-20)

គួរឲ្យចាប់អារម្មណ៍ណាស់ដែលថា នៅទីនេះ យើងឃើញពាក្យ “សង្ឃ” ត្រូវបានប្រើជាលើកដំបូងនៅក្នុងព្រះគម្ពីរ។ ភាពជាសង្ឃរបស់មិលគីស្សាដែក គឺជាភាពជាសង្ឃដំបូងបង្អស់ និងជាគំរូដើមនៃភាពជាសង្ឃទាំងអស់។ ចំណែកឯភាពជាសង្ឃរបស់ពួកលេវី ដែលត្រូវបានណែនាំប្រហែល ៥០០ ឆ្នាំក្រោយមក ក្រោមក្រឹត្យវិន័យរបស់លោកម៉ូសេវិញ គឺវាជាភាពជាសង្ឃដែលទាបជាង។

ទំនាក់ទំនងដ៏ច្បាស់លាស់

អ្នកសរសេរកណ្ឌគម្ពីរហេព្រើរ បានបង្ហាញពីភាពខុសគ្នាយ៉ាងច្បាស់ជាច្រើន រវាងភាពជាសង្ឃរបស់លោកមិលគីស្សាដែក និងភាពជាសង្ឃរបស់ពួកលេវី។ អ្វីដែលសំខាន់បំផុតនោះ គឺព្រះគម្ពីរបញ្ជាក់ថា ព្រះយេស៊ូវជាសង្ឃ មិនមែនតាមរបៀបរបស់លេវីទេ ប៉ុន្តែតាមរបៀបរបស់មិលគីស្សាដែក។ ដូចមានចែងនៅក្នុងហេព្រើរ ៧:១៧ ថា៖

> “ដ្បិតមានសេចក្តីបន្ទាល់ពីទ្រង់ [ព្រះយេស៊ូវ] ថា ឯងជាសង្ឃនៅអស់កល្បជានិច្ច តាមរបៀបលោកមិលគីស្សាដែក”។

អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺ ប្រសិនបើអ្នកសិក្សាពីបទបញ្ជានៃភាពជាសង្ឃតាមរបៀបពួកលេវី អ្នកនឹងឃើញថា សង្ឃលេវីមិនដែលមានអ្វីផ្តល់ឲ្យរាស្ត្ររបស់ព្រះ លើសពីអ្វីដែលរាស្ត្ររបស់ព្រះបានយកមកថ្វាយពួកគេជាមុននោះឡើយ។ ប៉ុន្តែលោក មិលគីស្សាដែក បានឲ្យដល់លោកអាប់រ៉ាម នូវអ្វីដែលលោកអាប់រ៉ាមមិនធ្លាប់បានថ្វាយដល់គាត់សោះ គឺ នំបុ័ង និងស្រាទំពាំងបាយជូរ។

ដោយបានដាក់គ្រឹះនៃការយល់ដឹងនេះហើយ ឥឡូវនេះ សូមយើងបង្វែរការយកចិត្តទុកដាក់ទៅកាន់ការរៀបរាប់អំពីពិធីលៀងព្រះអម្ចាស់។ យើងនឹងអានគម្ពីរម៉ាថាយ ២៦:២៦-២៩ ដែលពិពណ៌នាអំពីព្រឹត្តិការណ៍នៅក្នុងអាហារពេលល្ងាចចុងក្រោយ ជាពេលដែលព្រះយេស៊ូវបានបង្កើតពិធីលៀងព្រះអម្ចាស់ (Eucharist)។ ខគម្ពីរទាំងនេះបង្ហាញអំពីពេលវេលាដ៏ជ្រាលជ្រៅ និងមានអត្ថន័យបំផុតមួយនៅក្នុងគម្ពីរទាំងមូល។

> គ្រាដែលកំពុងតែបរិភោគ នោះព្រះយេស៊ូវទ្រង់យកនំបុ័ង ហើយកាលទ្រង់បានប្រទានពរ [បានប្រទានពររួច ឬបានអរព្រះគុណរួច] នោះក៏កាច់ប្រទានទៅពួកសិស្ស ដោយបន្ទូលថា ចូរយកបរិភោគចុះ នេះហើយជារូបកាយខ្ញុំ រួចទ្រង់យកពែងមកប្រទានពរ ក៏ហុចទៅឲ្យគេ ដោយបន្ទូលថា ចូរបរិភោគពីពែងនេះទាំងអស់គ្នាចុះ ដ្បិតនេះជាឈាមខ្ញុំ គឺជាឈាមនៃសញ្ញាថ្មី ដែលបានច្រួចចេញ សម្រាប់មនុស្សជាច្រើន ប្រយោជន៍នឹងផ្តាច់បាប តែខ្ញុំប្រាប់អ្នករាល់គ្នាថា ពីនេះទៅមុខ ខ្ញុំមិនផឹកពីផលផ្លែទំពាំងបាយជូរទៀតទេ ដរាបដល់ថ្ងៃណាដែលខ្ញុំនឹងផឹកជាថ្មី ជាមួយនឹងអ្នករាល់គ្នានៅក្នុងនគរព្រះវរបិតានៃខ្ញុំ។ (ម៉ាថាយ 26:26-29)

ការលេចឡើងវិញនៃភាពជាសង្ឃដំបូង

តើការដែលព្រះយេស៊ូវយកនំបុ័ង ហើយបន្ទាប់មកស្រាទំពាំងបាយជូរមកប្រគល់ឲ្យពួកសិស្ស មានអត្ថន័យអ្វី? តើទ្រង់កំពុងមានបន្ទូលអ្វីទៅកាន់ពួកគេ? ទ្រង់កំពុងមានបន្ទូលថា៖ "នៅក្នុងខ្ញុំ អ្នករាល់គ្នាកំពុងឃើញភាពជាសង្ឃរបស់លោកមិលគីស្សាដែក លេចឡើងវិញ។ ក្នុងអំឡុងពេលដែលក្រឹត្យវិន័យជាសម្ពន្ធមេត្រី ភាពជាសង្ឃនេះត្រូវបានផ្អាកទុកមួយរយៈ។ ប៉ុន្តែឥឡូវនេះ ក្នុងសម្ពន្ធមេត្រីថ្មី ភាពជាសង្ឃរបស់មិលគីស្សាដែកកំពុងត្រូវបានស្តារឡើងវិញ”។

តាមរយៈការយកនំបុ័ង និងស្រាទំពាំងបាយជូរមកប្រគល់នៅក្នុងអាហារពេលល្ងាចចុងក្រោយ ព្រះយេស៊ូវបានតាំងសម្ពន្ធមេត្រីថ្មីដោយព្រះលោហិតរបស់ទ្រង់។ នៅពេលទ្រង់យកពែង នោះទ្រង់មានបន្ទូលថា៖ “ដ្បិតនេះជាឈាមខ្ញុំ គឺជាឈាមនៃសញ្ញាថ្មី ដែលបានច្រួចចេញ សម្រាប់មនុស្សជាច្រើនប្រយោជន៍នឹងផ្តាច់បាប”។

នេះហើយគឺជាមូលដ្ឋានតាមព្រះគម្ពីរសម្រាប់ការយល់ដឹងអំពីពិធីលៀងព្រះអម្ចាស់។ ពិធីនេះគឺជាការស្តារឡើងវិញនូវភាពជាសង្ឃរបស់មិលគីស្សាដែក ដែលជាសង្ឃដ៏ខ្ពង់ខ្ពស់បំផុត និងជាភាពជាសង្ឃដើមតាំងពីដំបូង។ លើសពីនេះទៅទៀត និមិត្តសញ្ញាដែលព្រះយេស៊ូវបានប្រគល់ដល់ពួកសិស្ស គឺជានិមិត្តសញ្ញាដដែល ដែលមិលគីស្សាដែកបានប្រគល់ដល់លោកអាប់រ៉ាម គឺ នំបុ័ង និងស្រាទំពាំងបាយជូរ។ តាមរយៈពិធីលៀងព្រះអម្ចាស់ ព្រះយេស៊ូវបានស្តារឡើងវិញនូវភាពជាសង្ឃតាមរបៀបមិលគីស្សាដែក ព្រមទាំងស្តារឡើងវិញនូវនិមិត្តសញ្ញាដ៏វិសុទ្ធ ដែលយើងប្រើក្នុងការធ្វើពិធីលៀងព្រះអម្ចាស់រហូតមកដល់សព្វថ្ងៃ។

ការពិចារណាឃើញរូបអង្គនៃព្រះអម្ចាស់

ខ្ញុំផ្ទាល់ជឿថា នៅពេលខ្ញុំទទួលទានពិធីលៀងព្រះអម្ចាស់ ដោយបានបំពេញលក្ខខណ្ឌដែលព្រះបានកំណត់រួចហើយ នំបុ័ងដែលខ្ញុំកំពុងទទួលទាននោះ គឺជារូបកាយរបស់ព្រះអម្ចាស់។ ខ្ញុំមិនមែនកំពុងធ្វើពិធីដែលគ្រាន់តែជានិមិត្តសញ្ញាប៉ុណ្ណោះទេ ប៉ុន្តែខ្ញុំកំពុងចូលរួមក្នុងអ្វីដែលពិតប្រាកដ។ វាមិនមែនគ្រាន់តែជានិមិត្តសញ្ញាទេ តែជារូបកាយរបស់ព្រះអម្ចាស់។ នេះហើយជាអត្ថន័យនៃ “ការពិចារណាឃើញរូបអង្គនៃព្រះអម្ចាស់យ៉ាងត្រឹមត្រូវ” (១ កូរិនថូស 11:29)។

នៅពេលយើងកំពុងទទួលពិធីលៀងព្រះអម្ចាស់ យើងត្រូវមើលឲ្យហួសពីអ្វីដែលភ្នែកមើលឃើញ។ នៅពេលខ្ញុំមើលទៅបងប្អូនប្រុសស្រីដែលអង្គុយក្បែរខ្ញុំ ឬនៅជួរខាងមុខ ខ្ញុំមិនគួរមើលឃើញគ្រាន់តែមនុស្សម្នាក់ប៉ុណ្ណោះទេ ប៉ុន្តែត្រូវមើលឃើញថា គាត់គឺជា “សមាជិកម្នាក់នៃរូបកាយរបស់ព្រះគ្រីស្ទ”។ ខ្ញុំត្រូវដឹងថា គាត់គឺជាមនុស្សដែលព្រះយេស៊ូវបានសុគតជំនួស និងបានបង្ហូរព្រះលោហិតរបស់ទ្រង់ដើម្បីសង្គ្រោះពួកគេ។ នៅពេលនោះ ខ្ញុំត្រូវដឹងថា ប្រសិនបើខ្ញុំមិនឲ្យតម្លៃ និងមិនគោរពបងប្អូននោះទេ នោះខ្ញុំកំពុងធ្វើឲ្យព្រះទ័យរបស់ព្រះអម្ចាស់ព្រួយ។

បន្ទាប់មក លោកប៉ុលបានលើកឡើងពីចំណុចសំខាន់មួយទៀត ដោយមានប្រសាសន៍ថា៖

> “ត្រូវឲ្យមនុស្សល្បងខ្លួនឯងមើល រួចសឹមបរិភោគនំប៉័ង ហើយផឹកពីពែងនេះចុះ” (១កូរិនថូស11:28)។

ខ្ញុំពិតជាអរព្រះគុណព្រះ ដែលទ្រង់មិនបានបង្គាប់ឲ្យខ្ញុំពិនិត្យមើលអ្នកដទៃ។ តាមពិតទៅ ខ្ញុំមានការងារពេញម៉ោងរួចហើយ គឺ ការពិនិត្យមើលខ្លួនឯង។

ការចូលមកកាន់តុរបស់ព្រះអម្ចាស់

នៅពេលអ្នកគិតអំពីការចូលមកកាន់តុរបស់ព្រះអម្ចាស់ តើមានឥរិយាបថណាមួយនៅក្នុងចិត្តរបស់អ្នកដែលត្រូវប្រែចិត្តដែរឬទេ? តើមាននរណាម្នាក់ដែលអ្នកនៅតែស្អប់ឬ? តើមាននរណាម្នាក់ដែលអ្នកមិនទាន់អត់ទោសឲ្យឬ? ឬតើអ្នកកំពុងតែតស៊ូឬមានការមិនចុះសម្រុងជាមួយព្រះផ្ទាល់ឬទេ? បញ្ហាទាំងនេះត្រូវតែដោះស្រាយជាមុន។

ហេតុអ្វីមិនដោះស្រាយរឿងទាំងនេះឥឡូវនេះ ដោយការអធិស្ឋានរួមគ្នា? សូមឲ្យយើងទូលសូមព្រះឲ្យទ្រង់ចាប់ផ្តើមរៀបចំចិត្តរបស់យើង សម្រាប់ការចូលរួមក្នុងពិធីលៀងព្រះអម្ចាស់ ដោយការអធិស្ឋានដូចខាងក្រោម៖

ឱព្រះវរបិតានៃយើងខ្ញុំដែលគង់នៅស្ថានសួគ៌អើយ! ទូលបង្គំសូមអរព្រះគុណព្រះអង្គយ៉ាងជ្រាលជ្រៅ សម្រាប់ពិធីដ៏វិសុទ្ធ និងមានតម្លៃនេះ គឺ ពិធីលៀងព្រះអម្ចាស់ ដែលព្រះយេស៊ូវបានប្រទានដល់យើង នៅយប់មុនពេលទ្រង់ត្រូវឆ្កាង។

ទូលបង្គំសូមប្តេជ្ញាចិត្តថា នឹងចូលរួមក្នុងពិធីដ៏វិសុទ្ធនេះឲ្យបានញឹកញាប់ជាងមុន ដើម្បីប្រកាសអំពីការសុគតរបស់ព្រះអង្គ រំឭកដល់ព្រះអង្គ ទន្ទឹងរង់ចាំការយាងត្រឡប់មកវិញរបស់ព្រះអង្គ ទទួលស្គាល់រូបកាយរបស់ព្រះគ្រីស្ទ ចូលរួមក្នុងការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ មានសាមគ្គីភាពជាមួយអ្នកជឿទាំងអស់ និងញែកខ្លួនចេញពីការស្វែងរករបស់នៅលោកិយ។ សូមអរព្រះគុណទ្រង់ នៅពេលទូលបង្គំទទួលពិធីនេះ ទូលបង្គំកំពុងទទួលជីវិតពីទ្រង់ និងអបអរសាទរជីវិតដ៏អស់កល្បជានិច្ចដែលទ្រង់បានប្រទានឲ្យទូលបង្គំ។

ឥឡូវនេះ ទូលបង្គំរៀបចំចិត្តរបស់ទូលបង្គំដើម្បីជួបទ្រង់ នៅគ្រប់ឱកាសដែលទូលបង្គំនឹងមាន ក្នុងការចូលរួមក្នុងពិធីលៀងព្រះអម្ចាស់ដ៏អស្ចារ្យនេះ។ ទូលបង្គំសូមអធិស្ឋាននៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន!

ការបង្រៀនតាមរយៈសំបុត្រ
ប្រតិចារិក: TL-L161-100-KHM
បច្ចុប្បន្នភាពចុងក្រោយ: 12 Nov 2026
គេហទំព័រ: Derekprince.com/km/resources

